# របាយការណ៍

## សិក្ខាសាលាតំរង់ទិសនិងបណ្តុះបណ្តាល
## ស្តីពីការបង្ការជាវិជ្ជមាន និង ការផ្តល់សេវាពន្យារ
## កំណើតសំរាប់បុគ្គលិកនៃសេវាព្យាបាលជំងឺឱកាស
## និយមនិងឱសថប្រឆាំងមេរោគអេដស៍ និង
## គ្លីនិកសុខភាពគ្រួសារ
## ខេត្តសៀមរាប

The orientation workshop and training on
Positive Prevention and Birth Spacing for OI/ART and
Family Health Clinic Staffs

Siem Reap RH, Siem Reap Province 20-21 September 2011

រៀបចំដោយ | សហការណ៍ដោយ | ឧបត្ថម្ភដោយ

**១,ទីកន្លែងបណ្តុះបណ្តាល** : សាលប្រជុំនៃ អង្គរម៉ុលឌីយ៉ាល

**២,កាលបរិច្ឆេទ** : ថ្ងៃទី ២០-២១ ខែ កញ្ញា ឆ្នាំ ២០១១

**៣,គោលបំណង** :

- ផ្សព្វផ្សាយពីគោលគំនិតសំខាន់ៗស្តីពី ការបង្ការជាវិជ្ជមាន និង ការផ្តល់សេវាពន្យាកំណើតនៅតាមសេវាព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំងមេរោគអេដស៍ និងគ្លីនិកសុខភាពគ្រួសារ ។
- ផ្តល់ចំណេះដឹង និងជំនាញស្តីពីមធ្យោបាយពន្យាកំណើតដល់បុគ្គលិកដែលបំរើការនៅសេវា OI /ART និង STD ,
- ពិភាក្សា និងរកការឯកភាពគ្នាលើយន្តការនៃការស្នើសុំ និងរបាយការណ៍ស្តីពី ការប្រើប្រាស់មធ្យោបាយពន្យាកំណើត និង ការប្រមូលទិន្នន័យសំរាប់តាមដាន ។

**៤,រៀបចំដោយ** : មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោ

**៥, សហការណ៍ដោយ:** មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក

**៦,ឧបត្ថម្ភដោយ** : **Clinton HIV/AIDS Initiative (CHAI)**

**៧,សិក្ខាកាមចូលរួម:** ៥៥ រូបរួមមាន:

-មន្រ្តី មជអសក : ៨ នាក់

-មន្រ្តី មជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក: ២នាក់

-មន្រ្តី មន្ទីរសុខាភិបាលខេត្តសៀមរាប : ៦ នាក់

-មន្រ្តី មន្ទីរពេទ្យខេត្តសៀមរាប : ២៣ នាក់

-មន្រ្តីស្រុកប្រតិបត្តិសៀមរាប : ៣ នាក់

-មន្រ្តីមណ្ឌលសុខភាព ១ : ៣ នាក់

-មន្រ្តីអង្គការក្រៅរដ្ឋាភិបាល : ១០ នាក់

**៨,សកម្មភាព** :

ថ្ងៃទី ១ ទី ១២ ខែ កញ្ញា ឆ្នាំ ២០១១

-មតិស្វាគមន៍ដោយលោកវេជ្ជ **ក្រុស សារ៉ាត់** អនុប្រធានមន្ទីរសុខាភិបាលខេត្ត សៀមរាប

-ចំណាប់អារម្មណ៍របស់លោកវេជ្ជ **សេង វុធី** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ( មជអសក)

-មតិសំណេះសំណាល និង ការប្រកាសបើកដោយ លោកសាស្រ្តាចារ្យ **កេត លីសុត្ថា** តំណាងមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក ។

-ការណែនាំខ្លួនដោយលោកវេជ្ជ **សេង វុធី** អនុប្រធានផ្នែកថែទាំអ្នកជំងឺអេដស៍ មន្រ្តី នៃមជអសក

-ការបង្ហាញពីកម្មវិធី និង គោលបំណងដោយវេជ្ជ **ស៊ិត សុវណ្ណរិទ្ធិ** ប្រធានផ្នែកថែទាំអ្នកជំងឺអេដស៍នៃមជអសក

-ការបង្ហាញពីបច្ចុប្បន្នភាពនៃស្ថានភាពមេរោគអេដស៍នៅប្រទេសកម្ពុជា ដោយវេជ្ជ **ទូច សារុន**

-ទស្សនៈស្តីពីការបង្ការជាវិជ្ជមានចំពោះមេរោគអេដស៍ ដោយវេជ្ជ **សេង វុធី**

-ការប្រើប្រាស់ស្រោមអនាម័យ និង ជំហាននៃការប្រើប្រាស់ស្រោមអនាម័យអោយបានត្រឹមត្រូវបង្ហាញដោយវេជ្ជ **ទូច សារុន**

-ការបង្ហាញពីទំរង់របាយការណ៍ យន្តការបញ្ជូនអ្នកជំងឺក្នុងមន្ទីរពេទ្យ និង ពិភាក្សាពីការបំពេញទំរង់របាយការណ៍ដោយលោក **ផាត់ វាសនា** មន្ត្រីគ្រប់គ្រងទិន្នន័យនៃ មជអសក និងសំរបសំរួលដោយ វេជ្ជ **ស៊ិត សុវណ្ណរិទ្ធិ** មន្ត្រីនៃ មជអសក។

**ថ្ងៃទី ២ ទី ២១ ខែ កញ្ញា ឆ្នាំ ២០១១**

-គោលការណ៍គ្រឹះ នៃការពន្យាកំណើត និង សិទ្ធិរបស់អ្នកជំងឺក្នុងការទទួលសេវា បង្ហាញដោយលោកស្រី **លី សុគន្ធ** អនុប្រធាននៃកម្មវិធីគាំពារមាតា និង ទារក ខេត្តសៀមរាប និង សំរបសំរួលដោយលោក វេជ្ជ **ទូច សារុន** មន្ត្រី មជអសក។

- និយមន័យ នៃ ការពន្យាកំណើត និង ប្រព័ន្ធការពន្យាកំណើតបង្ហាយដោយ លោក ប៊ុត ស៊ីណា

-ការប្រើប្រាស់ឱសថពន្យាកំណើតគ្រាប់ដោយលេបរួមមាន: Oral Contraceptive(COC and Emergency Pill, Oral contraceptive POP និង ការប្រើប្រាសឱសថពន្យាកំណើតដោយចាក់ បង្ហាញដោយ លោកស្រី **លី សុគន្ធ** សំរបសំរួលដោយលោកវេជ្ជ **សេង វុធី** ។

-ការបំពេញទំរង់របាយការណ៍ពន្យាកំណើត និងទំរង់ផ្សេងៗ ទាក់ទងនឹងការឱសថពន្យាកំណើត បង្ហាញដោយ លោកស្រី លី សុគន្ធ មន្ត្រីនៃកម្មវិធីគាំពារមាតា និង ទារកខេត្ត សៀមរាប និង សំរបសំរួលដោយលោក វេជ្ជ **សេង វុធី** មន្ត្រី មជអសក។

**៨.ចំណុចល្អជាវិជ្ជមានៈ**

- មណ្ឌលសុខភាពនៅក្នុងមន្ទីរពេទ្យខេត្តសៀមរាបដែលបង្កលក្ខណៈងាយស្រួលដល់ការផ្តល់ឱសថ និង មធ្យោបាយពន្យាកំណើតដល់ក្រុម OI/ART
- មានការផ្តល់សេវាគ្រប់មធ្យោបាយពន្យាកំណើតនៅក្នុងមន្ទីរពេទ្យខេត្តស្រាប់ ដោយទទួលឱសថនិងគ្រប់មធ្យោបាយពន្យាកំណើតពី ឃ្លាំងឱសថកណ្តាលរួចហើយៗកំពុងដំណើរការផ្តល់សេវាដល់ស្ត្រីទូទៅនៅក្នុងមន្ទីរពេទ្យ ។
- របាយការណ៍ត្រីមាសទី ២ ឆ្នាំ២០១១ របស់មន្ទីរពេទ្យបង្អែកសៀមរាបរួមមានៈអ្នកផ្ទុកមមេរោគអេដស៍ពេញវ៍យសរុប ២៨២៥ នាក់ (OI= 393 cases and ART= 1150 cases)។ ដោយឡែកស្ត្រីផ្ទុកមេរោគអេដស៍ពេញវ៍យសរុប ១៣៦៤ នាក់ ដែលត្រូវការពន្យាកំណើត ។
- មានការបញ្ជូនស្ត្រីមានផ្ទៃពោះសង្ស័យ ពីសហគមន៍ ដោយក្រុមថែទាំអ្នកជំងឺអេដស៍តាមផ្ទះដោយអង្គការ BFD, HACC, Caritas by based of link Response and HBC approach.

- មានការសហការណ៍ល្អរវាងផ្នែកគាំពារមាតា និងទារកខេត្ត និង កម្មវិធីអេដស៍ខេត្ត។

**៩,បញ្ហានានា:**

- ការប្រើប្រាស់ស្រោមអនាម័យកន្លងមិនគ្រប់គ្រាន់ទេចំពោះអ្នកផ្ទុកមេរោគអេដស៍ សំណូមពរសុំ ១០ ស្រោមទើបប្រើគ្រាន់ ។

**១០,ចំណុចត្រូវតាមដាន និងសកម្មភាពបន្ត:**

- ឱសថពន្យាកំរេណើតមាននៅមន្ទីរពេទ្យខេត្តស្រាប់ ។
- ឱសថពន្យាកំណើតត្រូវស្នើសុំពីក្រុម OI/ART team ទៅមន្ទីរពេទ្យខេត្ត សៀមរាបហើយយកមកបំរើនៅផ្នែក OI/ART សំរាប់ស្ត្រីផ្ទុកមេរោគអេដស៍ ។
- សុំបញ្ចូលឱសថពន្យាកំណើតទៅក្នុងកញ្ចប់ CMS ដោយផ្ទាល់។
- MCH ខេត្ត សហការណ៍ជាមួយ PASP ត្រូវជួយសំរបសំរួលផ្តល់ឱសថពន្យាកំណើតដូចជា Pill Depo ដោយជួយវាយតំលៃពីតំរូវការជាក់ស្តែងការប្រើប្រាស់ និង តាមដានផ្តល់បច្ចេកទេស ដល់បុគ្គលិក OI/ART បន្ថែមទៀតតាមរយៈការចុះអភិបាលរួមពីកម្មវិធីអេដស៍ខេត្តដោយប្រើប្រាស់ថវិកាមូនិធិសកល ឬ អង្គការនានា ។

**១១,សេចក្តីសន្និដ្ឋាន:**

វគ្គសិក្ខាសាលាតំរង់ទិស និង បណ្តុះបណ្តាលការបង្ការជាវិជ្ជមាន និង ការផ្តល់សេវាពន្យាកំណើតសំរាប់បុគ្គលិកសេវាព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំងមេរោគអេដស៍បានដំណើរប្រកបទៅដោយជោគជ័យ ក្រោមការប្រកាសបិទដោយលោកសាស្ត្រាចារ្យ **កែត លីសុត្ថា** អនុប្រធានមជ្ឈមណ្ឌលជាតិគាំពាមាតា និង ទារក និង លោកវេជ្ជ **សរិត សុវណ្ណរិទ្ធិ** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺអេដស៍សើស្បែក និងកាមរោគ ក្រោម ការប្តេជ្ញាចិត្តរបស់ក្រុម OI/ART ថាដំណើរការអនុវត្តសកម្មភាពបង្ការជាវិជ្ជមានក្នុងខែតុលាឆ្នាំ ២០១១នេះ ។

ភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១

បានឃើញ និង ឯកភាព

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ

នឹងជំងឺអេដស៍ សើស្បែក និង កាមរោគ

វេជ្ជ.លី_ពេញ ស៊ុន

អ្នកធ្វើរបាយការណ៍

លោកវេជ្ជ ទូច សារុន